អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
## (របាយការណ៍សម្រាប់ ខែឧសភា ឆ្នាំ២០០៨)

បន្ថែមទៅលើរបាយការណ៍មុនរបស់សហចៅក្រមស៊ើបអង្កេតនាថ្ងៃទី ២៤ មេសា និង ១៥ និង ១៦ ឧសភា ២០០៨ សហចៅក្រមស៊ើបអង្កេតបានទទួលសំណួរជាច្រើនដែលថា នៅពេលណាសំណុំរឿងទីមួយទាក់ទងនឹង ឌុច និង ស ២១ ត្រូវបញ្ជូនទៅសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេតសូមបញ្ជាក់ដូចខាងក្រោម ៖

បន្ទាប់ពីបានបញ្ចប់កិច្ចស៊ើបសួរដែលនៅសេសសល់រួចមក កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីនានាអំពីការបញ្ចប់នៃកិច្ចស៊ើបសួរ (វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង)។ បន្ទាប់ពីថ្ងៃដែលបានជូនដំណឹងនោះរួចមក ភាគីនានា (រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង) មានរយៈពេល ១៥ ថ្ងៃ ដើម្បីស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម និងជាក់ស្តែងមានសំណើសុំចំនួនពីរ ត្រូវបានទទួលនៅពេលបញ្ចប់រយៈពេលនេះ ការិយាល័យសហព្រះរាជអាជ្ញាដោយសំអាងលើអង្គហេតុដដែល បានស្នើសុំថា **ឌុច** ត្រូវតែបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋជាតិ រួមនឹងបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យរួចហើយ ចំណែកភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរ បានស្នើសុំឱ្យសួរចម្លើយ **ឌុច** បន្ថែមទៀត។

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដែលមានសំអាងហេតុបដិសេធសំណើសុំទាំងពីរនេះ ហើយដីកាទាំងនេះត្រូវបានចុះផ្សាយនៅលើគេហទំព័ររបស់អ.វ.ត.ក។

រហូតមកដល់ពេលនេះ ភាគីដែលពាក់ព័ន្ធមិនទាន់បានបញ្ជាក់អះអាងថា ខ្លួននឹងប្តឹងឧទ្ធរណ៍ចំពោះដីការបស់សហចៅក្រមស៊ើបអង្កេត ឬ ក៏លះបង់ចោលសិទ្ធិប្តឹងឧទ្ធរណ៍ដែលអាចធ្វើក្នុងរយៈពេល ៣០ ថ្ងៃនៅឡើយ(ដែលនេះជាសិទ្ធិរបស់ពួកគេ)។ ដោយនៅរង់ចាំការបញ្ជាក់អះអាងនេះ សហចៅក្រមស៊ើបអង្កេត មិនអាចបញ្ជូនជាផ្លូវការនូវសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញាទេ ហើយជំហានបន្ទាប់ទៀត (ដីកាសន្និដ្ឋានស្ថាពររបស់ការិយាល័យសហព្រះរាជអាជ្ញា និងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត) មិនអាចជឿនលឿនទៅមុខបានទេ។ ដោយសារមូលហេតុនេះ សហចៅក្រមស៊ើបអង្កេត មិនអាចបញ្ជាក់អះអាងថា តើការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ដែលបានគ្រោងនៅដំណាច់ខែកក្កដា ឆ្នាំ ២០០៨ អាចត្រូវបានរក្សាទុកតាមការគ្រោងទុកឬយ៉ាងណា។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត

នៅតែបន្តផ្តល់អាទិភាពដល់ការងារនេះ និងប្រមូលផ្តុំធនធានរបស់ខ្លួនដើម្បីធានាថា ការរៀបចំតាក់តែងដីកាដំណោះស្រាយមានការរីកចំរើនទៅមុខបានយ៉ាងឆាប់រហ័ស។